**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគទីតាំងកោះមួយចំនួន ក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ និងខេត្តកំពត ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៅ "ក.អ.ក" នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៧
- យោងតាមតំរូវការចាំបាច់នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍

## សម្រេច

**មាត្រា១:** ត្រូវបានធ្វើអនុបយោគទីតាំងកោះមួយចំនួន ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីបំរើការងារអភិវឌ្ឍន៍វិញ ដូចខាងក្រោម :

១- កោះសេះ ស្ថិតក្នុងភូមិសាស្ត្រ ខេត្តកំពត ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី103°47’05”E ដល់ 103°49’28” និងចន្លោះខ្សែរយៈទទឹង(ជើង) ទី10°24’11”N ដល់ 10°26’19” ទំហំសរុប ៧៥៨.២ហិកតា។

២- កោះតាកៀវ ស្ថិតក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី 103°34’41” ដល់ 103°36’30” និងចន្លោះខ្សែរយៈទទឹង(ជើង)ទី 10°28’28” ដល់ 10°30’37”ទំហំសរុប ៧១៥,៣០ម$^{២}$ ។

៣- កោះថាស(កោងកាង) ស្ថិតក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី103°24’31” ដល់ 103°25’57” និងចន្លោះខ្សែរយៈទទឹង(ជើង) ទី10°36’17” ដល់ 10°36’ 43” ទំហំសរុប១០២ហិកតា។

៤- កោះបង ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់កោះរុង ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី103°15’46” ដល់ 103°15’54” និងចន្លោះខ្សែរយៈទទឹង(ជើង) ទី10°45’29” ដល់ 10°45’36” ទំហំសរុប ៤,២៤ហិកតា។

៥- កោះអូន ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់កោះរុង ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី103°15’41” ដល់ 103°15’47” និងចន្លោះខ្សែរយៈទទឹង(ជើង)ទី10°45’18” ដល់ 10°45’27” ទំហំសរុប ៣,១៨ហិកតា។

៦- កោះដែកគោល ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់លេខ៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ អភិបាលខេត្តកំពត អភិបាលគ្រប់ខេត្ត-ក្រុង និងប្រធានអង្គភាពទាំងអស់ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣ "ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ